**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ទីស្តីការគណៈរដ្ឋមន្ត្រី**
លេខ: ១៥៥៦ សជណ

រាជធានីភ្នំពេញ, ថ្ងៃទី០៥ខែ ធ្នូ ឆ្នាំ ២០១២

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**
**ជំរាបជូន**
**ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**
**និងជាប្រធានក្រុមប្រឹក្សាគោលនយោបាយដីធ្លី**

**កម្មវត្ថុ ៖** ករណីសំណើសុំគោលការណ៍ចុះបញ្ជីក្បាលដីដែលត្រូវឆ្វៀលចេញ (ក្បាលដីស្បែកខ្លា) ជាដីរបស់រដ្ឋ តំណាងដោយគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្ត ។

**យោង ៖** -លិខិតលេខ ១៥៣៩ កគដ/ជនស ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០១២ របស់ឯកឧត្តម រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងជា ប្រធានក្រុមប្រឹក្សាគោលនយោបាយដីធ្លី

-ចំណារដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០១២ ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ទីស្តីការគណៈរដ្ឋមន្ត្រី សូមជំរាបជូនឯកឧត្តម មេត្តាជ្រាបថា ចំពោះករណីនេះ រាជរដ្ឋាភិបាលបានសំរេចយល់ព្រមតាមសំណើរបស់ឯកឧត្តមរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងជា ប្រធានក្រុមប្រឹក្សាគោលនយោបាយដីធ្លី ដើម្បីអនុវត្តដូចតទៅ ៖

- ចុះបញ្ជីក្បាលដីដែលបានឆ្វៀលចេញ (ក្បាលដីស្បែកខ្លា) ក្នុងតំបន់វិនិច្ឆ័យ និងបានឆ្វៀលចេញពីក្បាលដីប្រទានកម្មជូនប្រជាពលរដ្ឋ ជូនទៅគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្ត ជាតំណាងដើម្បីថែរក្សា ការពារ និង គ្រប់គ្រងឲ្យមានប្រសិទ្ធភាព
- ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត ដែលជាសមាជិកអចិន្ត្រៃយ៍នៃគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្ត ត្រូវថតចម្លងប្លង់សុរិយោដីជូនដល់រដ្ឋបាលថ្នាក់ក្រោមជាតិ (ឃុំ/សង្កាត់ ស្រុក ខេត្ត) សំរាប់ការពិនិត្យតាមដាន
- គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្ត អាចប្រើប្រាស់ដីរដ្ឋទាំងនោះសម្រាប់កម្មវិធីសម្បទានដីសង្គមកិច្ច និង/ឬសម្រាប់ការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធរូបវន្តនិងសង្គម នៅក្នុងមូលដ្ឋាន ។

សេចក្តីដូចបានជំរាបជូនខាងលើ សូមឯកឧត្តម មេត្តាជ្រាប និងចាត់ចែងអនុវត្តន៍ តាមការគួរ។

**ជ.រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**
**រដ្ឋលេខាធិការ**

**ប៊ុន អ៊ុយ**

**ចំលងជូន ៖**
- ក្រសួងមហាផ្ទៃ
- ក្រសួងបរិស្ថាន
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- អាជ្ញាធរជាតិ ដោះស្រាយទំនាស់ដីធ្លី
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- រដ្ឋបាលព្រៃឈើ
- គណៈកម្មការត្រួតពិនិត្យការអនុវត្តនយោបាយចាស់ សកម្មភាពថ្មី លើវិស័យដីធ្លី
- គ្រប់សាលាខេត្ត-រាជធានី
- ឯកសារ-កាលប្បវត្តិ